**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...០៩.......សរណន

# សារាចរណែនាំ

## ស្តីពី

## ការប្រារព្ធទិវាអក្ខរកម្មជាតិ ៨ កញ្ញា

ក្នុងស្មារតីបំផុសចលនាអក្ខរកម្មអោយបានជ្រួតជ្រាបដល់គ្រប់ក្រសួង ស្ថាប័នរដ្ឋ ឯកជន ព្រមទាំងប្រជាពលរដ្ឋក្នុងទូទាំងប្រទេស ស្របតាមសេចក្តីសំរេចចិត្តនៃមហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៥៦/១១៦ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០២ ស្តីពី *"ទសវត្សអង្គការសហប្រជាជាតិសំរាប់អក្ខរកម្ម និងការអប់រំសំរាប់ទាំងអស់គ្នា"* និងតាមស្មារតីនៃព្រះរាជក្រឹត្យ លេខ នស.រកត ០៩០០/១៦៣ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការកំណត់យកថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០២ ជាទិវាអក្ខរកម្មជាតិនោះ រាជរដ្ឋាភិបាលកម្ពុជា ចេញសេចក្តីណែនាំដល់គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង អោយរៀបចំប្រារព្ធទិវា អក្ខរកម្មជាតិថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ២០០២ ក្រោមប្រធានបទ *"អនក្ខរជនទប់ទល់នឹងជម្ងឺអេដស៍"* ដែលមានខ្លឹមសារ ណែនាំដូចខាងក្រោម :

១- ក្រសួងអប់រំ យុវជន និង កីឡា ត្រូវរៀបចំការប្រជុំថ្នាក់ជាតិនៅកន្លែងណាមួយនាថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០២ ដើម្បីផ្សព្វផ្សាយលទ្ធផលអក្ខរកម្មនាឆ្នាំកន្លងមក និងប្រកាសអំពីផែនការយុទ្ធសាស្ត្រសំខាន់ៗ នៃការងារអប់រំក្រៅប្រព័ន្ធ ដែលត្រូវអនុវត្តនាពេលខាងមុខ ដោយមានការចូលរួមពីក្រសួង ស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ និង អន្តរជាតិ សិស្ស និស្សិត និងប្រជាពលរដ្ឋ ។

២- អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវចាត់ចែងរៀបចំ :

ក- បិទបដា ពាក្យស្លោក នៅតាមអង្គភាពរដ្ឋ ទីប្រជុំជន ដងផ្លូវសាធារណៈ ចាប់ពីថ្ងៃទី ៧ ដល់ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០០២ ។

ខ- ធ្វើមិទ្ទិញ ឬ ប្រជុំ ឬហែរក្បួន ដែលមានខ្លឹមសារពាក់ព័ន្ធទៅនឹងការបំផុសចលនាអក្ខរកម្ម និងការប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ ។

គ- ត្រូវរៀបចំបំផុសចលនា និងធ្វើការប្រឡងសិស្សអក្ខរកម្មតាមប្រធានបទ *"អនក្ខរជនទប់ទល់នឹងជម្ងឺអេដស៍"* តាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

- ចំពោះទីកន្លែងដែលមានថ្នាក់រៀនអក្ខរកម្ម ត្រូវចាត់ចែងប្រឡងសិស្សអក្ខរកម្មដើម្បីស្វែងយល់អំពីជម្ងឺអេដស៍ ហើយបេក្ខជនដែលទទួលបានពិន្ទុល្អក្នុងការប្រឡងត្រូវចាត់ចែងជូនរង្វាន់លើកទឹកចិត្តតាមការជាក់ស្តែង ។
- ចំពោះទីកន្លែងដែលពុំមានថ្នាក់រៀនអក្ខរកម្ម ត្រូវចាត់ចែងមន្ត្រីជំនាញឱ្យចុះឃោសនាអំពីសារសំខាន់នៃការរៀនសូត្រ និងគ្រោះថ្នាក់នៃជម្ងឺអេដស៍ ។

៣- ក្រសួងធម្មការ និង សាសនា ត្រូវណែនាំដល់ព្រះសង្ឃ និងពុទ្ធបរិស័ទអោយមានសទ្ធាជ្រះថ្លាក្នុងការជួយឧបត្ថម្ភដល់ការងារអក្ខរកម្ម និង ពន្យល់ណែនាំដល់អនក្ខរជនអោយយល់អំពីសារៈសំខាន់នៃការរៀនសូត្រ។

៤- ក្រសួងពតិមាន និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវពិនិត្យលទ្ធភាពរៀបចំការសំដែងសិល្បៈ បទអត្ថាធិប្បាយ បទយកការណ៍ ស្តីពីការងារអប់រំក្រៅប្រព័ន្ធនៅកម្ពុជា ផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍។

៥- អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា ដែលកំពុងបំពេញការងារអប់រំក្រៅប្រព័ន្ធនៅកម្ពុជា សូមជួយឧបត្ថម្ភដល់ពិធីបុណ្យនេះនៅតាមទីកន្លែងដែលអង្គការនោះប្រតិបត្តិ និងត្រូវធ្វើរបាយការណ៍ពីសកម្មភាពរបស់អង្គការផ្ញើទៅក្រសួងអប់រំ យុវជន និងកីឡា អោយបានមុនដំណាច់ខែ សីហា ២០០២។

៦- គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នានៅគ្រប់លំដាប់ថ្នាក់ ត្រូវប្រជុំបូកសរុបវាយតំលៃការងារអប់រំក្រៅប្រព័ន្ធ ដែលបានអនុវត្តកន្លងមក និងលើកទិសដៅឆ្នាំខាងមុខ។

ទទួលបានសារាចរណែនាំនេះ សូមឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង ផ្សព្វផ្សាយ និងរៀបចំណែនាំ ព្រមទាំងអនុវត្តសារាចរនេះអោយទទួលបានលទ្ធផលល្អប្រសើរ រួចហើយត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំពិធីនេះ ផ្ញើមកក្រសួងអប់រំ យុវជន និង កីឡា ដើម្បីបូកសរុបជូនគណៈរដ្ឋមន្ត្រីអោយបានមុនដំណាច់ខែ កញ្ញា ឆ្នាំ ២០០២។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

"ដើម្បីទូលថ្វាយ និង គោរពជូនជ្រាបជាពតិមាន"

- គ្រប់ក្រសួង ស្ថាប័ននានា
- គ្រប់អភិបាលខេត្ត-ក្រុង

"ដើម្បីអនុវត្ត"

- កាលប្បវត្តិ-ឯកសារ